## ២-សេចក្តីសំរេច

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មីនា ឆ្នាំ ១៩៩៩

### សេចក្តីសំរេចលេខ ១៧ សសរ.

### ស្តីពីការបង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែន កម្ពុជា-ថៃ

***

### រាជរដ្ឋាភិបាល

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៦/២៥ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៨ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការនីតិកម្មកិច្ចការព្រំដែន ចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- បានឃើញ អនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការបង្កើតគណៈកម្មាធិការបច្ចេកទេសកិច្ចការព្រំដែនចំណុះឲ្យអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន
- យោងតាមតំរូវការចាំបាច់

### សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មាធិការចំរុះកិច្ចការព្រំដែនកម្ពុជា-ថៃ ដែលមានសមាសភាព ដូចតទៅ :

១- ឯកឧត្តម វ៉ា គឹមហុង ទីប្រឹក្សារាជរដ្ឋាភិបាល ទទួលបន្ទុកកិច្ចការព្រំដែន ប្រធាន

២- ឯកឧត្តម ឧត្តមសេនីយ៍ឯក ម៉ុល សារឿន អគ្គមេបញ្ជាការរងនៃកងយោធពលខេមរភូមិន្ទ ទីប្រឹក្សា

៣- ឯកឧត្តម ឡុង វិសាលោ អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ អនុប្រធាន

៤- ឯកឧត្តម ម៉ុន សម អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក

៥- ឯកឧត្តម អភិបាលខេត្ត ព្រះវិហារ សមាជិក

៦- ឯកឧត្តម អភិបាលខេត្ត ឧត្តរមានជ័យ សមាជិក

៧- ឯកឧត្តម អភិបាលខេត្ត បន្ទាយមានជ័យ សមាជិក

៨- ឯកឧត្តម អភិបាលខេត្ត បាត់ដំបង សមាជិក

៩- ឯកឧត្តម អភិបាលខេត្ត ពោធិសាត់ សមាជិក

១០- ឯកឧត្តម អភិបាលខេត្ត កោះកុង សមាជិក

១១- ឯកឧត្តម ប្រតិភូរាជរដ្ឋាភិបាលប្រចាំក្រុង ប៉ៃលិន សមាជិក

១២- លោក ឈួន សាទ៉ាន ប្រធាននាយកដ្ឋានភូមិសាស្ត្រ ក្រសួងនគរូនីយកម្ម និងសំណង់ សមាជិកអចិន្ត្រៃយ៍

១៣- លោកឧត្តមសេនីយ៍ទោ ឆាម៉ន មេបញ្ជាការយោធភូមិភាគ៤ សមាជិក

១៤- លោកឧត្តមសេនីយ៍ទោ ម៉ុន សេខ មេបញ្ជាការយោធភូមិភាគ៥ សមាជិក

១៥- លោកឧត្តមនាវីទោ អ៊ឹ សំខាន់ មេបញ្ជាការកងទ័ពជើងទឹក សមាជិក

១៦- លោកឧត្តមសេនីយ៍ត្រី ចាន់ អ៊ាន ប្រធាននាយកដ្ឋានព្រំដែនគោក ក្រសួងមហាផ្ទៃ សមាជិក

១៧- លោកឧត្តមសេនីយ៍ទោ ឈុំ សុជាតិ ប្រធាននាយកដ្ឋានការពារព្រំដែន អគ្គសេនាធិការ សមាជិក

១៨- លោក រស់ គន់ ប្រធាននាយកដ្ឋានច្បាប់-កុងស៊ុលក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

១៩- លោក ឡុង ផុល ប្រធានាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

២០- លោក អ៊ុក សុម៉ារឹម ប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ សមាជិក

២១- លោកឧត្តមសេនីយ៍ត្រី ខេត ចំរើន ប្រធាននាយកដ្ឋានភូមិសាស្ត្រក្រសួងការពារជាតិ សមាជិក

២២- លោក ហ៊ុំ សាគុណ អនុប្រធានទី១ នាយកដ្ឋាននគរបាលព្រំដែនទឹក ក្រសួងមហាផ្ទៃ សមាជិក

២៣- លោក ស៊ា កុសល អនុប្រធាននាយកដ្ឋានច្បាប់-កុងស៊ុល ក្រសួង ការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក

**ប្រការ ២ :** គណៈកម្មាធិការចំរុះ កិច្ចការព្រំដែនកម្ពុជា-ថៃ មានភារកិច្ច ដូចខាងក្រោម :

ក- ពិនិត្យ និងដោះស្រាយរាល់បញ្ហាទាក់ទង និងការខ័ណ្ឌព្រំដែនសីមា និងបោះបង្គោលព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ ។

ខ- ចរចាជាមួយភាគីថៃ ដើម្បីដោះស្រាយនូវរាល់បញ្ហាទាក់ទងនឹងការខ័ណ្ឌសីមា និងបោះបង្គោលព្រំដែនគោក និងការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ ។

គ- រៀបចំសន្និសញ្ញាសលើការកំណត់ព្រំដែនសមុទ្រកម្ពុជា-ថៃ ដើម្បីដាក់ជូនរាជរដ្ឋាភិបាល ពិនិត្យសំរេច ។

ឃ- ដឹកនាំការងារខ័ណ្ឌព្រំដែនសីមា និងបោះបង្គោលព្រំដែន ។

ង- ដោះស្រាយនូវរាល់បញ្ហា ស្តីពីការអនុវត្តន៍លក្ខន្តិកៈព្រំដែនរវាងកម្ពុជា-ថៃ ។

ច- ធ្វើរបាយការណ៍តាមតំណាក់កាលនីមួយៗ អំពីសភាពការណ៍នៃការដោះស្រាយ និងការខ័ណ្ឌព្រំសីមា និងបោះបង្គោលព្រំដែនជាមួយប្រទេសថៃ ជូនអាជ្ញាធរជាតិទទួលបន្ទុកកិច្ចការព្រំដែន សំរាប់ការរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ។

**ប្រការ ៣ :** ដើម្បីបំពេញការងារខាងលើនេះ គណៈកម្មាធិការចំរុះអាចនឹងបង្កើតក្រុមបច្ចេកទេសសំរាប់ធ្វើជាសេនាធិការ ។

**ប្រការ ៤ :** គ្រប់សមាជិកនៃគណៈកម្មាធិការ ត្រូវចូលរួមតាមការកោះអញ្ជើញរបស់គណៈកម្មាធិការ។

**ប្រការ ៥ :** គណៈកម្មាធិការនេះមានទីស្នាក់ការរបស់ខ្លួននៅទីស្តីការគណៈរដ្ឋមន្ត្រី និងមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រី ។

**ប្រការ ៦ :** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ អង្គភាពសាមី និងសាមីខ្លួន ដូចមានចែងក្នុងប្រការ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

នាយករដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

ហ៊ុន សែន

★★★